# កឋិនប្រវត្តិ



*សម័យនោះ ព្រះពុទ្ធមានព្រះភាគគង់ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកភិក្ខុនៅក្នុងដែនបាឋា (យោជនាថា នៅក្នុងដែនបាវាជូច្នេះក៏មាន) ប្រមាណ ៣០ រូប (ភទ្ទវគ្គិយត្ថេរ ៣០ រូបជាបងប្អូនរួមបិតារបស់ព្រះបាទកោសល [មហាកោសល] ) សុទ្ធតែជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ជាអ្នកប្រព្រឹត្តបិណ្ឌបាត ជាអ្នកប្រព្រឹត្ត*

ប្រើសំពត់បង្សុកូលជាអ្នកប្រព្រឹត្តប្រើតែចីវរ ៣ (មិនមែនសមាទានតែធុតង្គទាំងនេះទេ គឺលោកគ្រប់អង្គជាអ្នកសមាទានធុតង្គទាំង១៣តែម្តង) គ្រប់រូបទាំងអស់ នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ កាលបើតិថីដែលចូលវស្សាជិតណាស់មកហើយ ក៏មិនអាចនឹងទៅឲ្យទាន់ចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ហើយនាំគ្នាចូលទៅចាំវស្សាក្នុងក្រុងសាកេត នាពាក់កណ្តាលផ្លូវ ។ ភិក្ខុទាំងនោះនៅចាំវស្សា ទាំងមានសេចក្តីអផ្សុក ព្រោះគិតថា ព្រះមានព្រះភាគព្រះអង្គគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ ៦ យោជន៍អំពីទីនេះទៅ យើងទាំងឡាយមិនសមបើមិនបានទៅគាល់ព្រះអង្គសោះ ។ គ្រានោះ ពួកភិក្ខុទាំងនោះនៅចាំវស្សាអស់ត្រៃមាសរួចហើយ ក៏នាំគ្នាធ្វើបវារណា (រដូវនោះ) នៅមានទឹកភ្លៀងធ្លាក់ជោកជាំ មានទឹកភក់រអិលនៅឡើយ (ភិក្ខុទាំងនោះ) ក៏មានចីវរទាំងឡាយទទឹកជោក បានសេចក្តីលំបាកកាយ នាំគ្នាដើរសំដៅទៅកាន់ក្រុងសាវត្ថី ហើយចូលទៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ ការស្រុះស្រួលទទួលជាមួយនឹងពួកភិក្ខុអាគន្តុកៈនេះ ជាទំនៀមរបស់ព្រះពុទ្ធដ៏មានព្រះភាគគ្រប់អង្គ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលនេះនឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកពល់គ្នាល្មមអត់ទ្រាំបានទេឬ អ្នកពល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។

ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមអត់ទ្រាំបាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងអស់គ្នាសាមគ្គីស្មោះសរឥតមានវិវាទទាស់ទែងគ្នាទេ នៅចាំវស្សា

ក៏ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយនៅក្នុងដែនបាឋាប្រមាណ ៣០ រូបមកកាន់ក្រុងសាវត្ថីនេះ ដើម្បីគាល់ព្រះអង្គ កាលបើតិថីចូលវស្សាជិតណាស់ហើយ ក៏មិនអាចនឹងមកទាន់ពេលចូលវស្សាក្នុងក្រុងសាវត្ថីបានឡើយ ក៏នៅចាំវស្សាក្នុងក្រុងសាកេតនាពាក់កណ្តាលផ្លូវ (នោះទៅ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងនោះនៅចាំវស្សាទាំងមានសេចក្តីអផ្សុក ព្រោះគិតថា ព្រះដ៏មានព្រះភាគព្រះអង្គគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ ៦ យោជន៍អំពីទីនេះទៅ យើងទាំងឡាយមិនសមបើមិនបានទៅគាល់ព្រះអង្គសោះ បពិត្រព្រះអង្គដ៏ចម្រើន លុះខ្ញុំព្រះអង្គទាំងអស់គ្នានៅចាំវស្សាអស់ត្រៃមាសហើយ ក៏នាំគ្នាធ្វើបវារណា (ព្រោះរដូវនេះ) នៅមានទឹកភ្លៀងធ្លាក់ជោកជាំ មានទឹកកក់រអិលនៅឡើយ ទើបខ្ញុំព្រះអង្គទាំងអស់គ្នាមានចីវរទាំងឡាយទទឹកជោក បានសេចក្តីលំបាកកាយមកតាមផ្លូវឆ្ងាយ ។

(វិនយបិដក មហាវគ្គ កឋិនក្ខន្ធកៈ បិដកលេខ ៨ ទំព័រ ១-៣)

ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាថា

ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ថាដូចម្តេច ម្នាលភិក្ខុទាំងឡាយ ត្រង់ដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ ត្រូវគេកាត់ក្បាលដោយជាអង្វែងនេះ ឈាមដែលហូរស្រក់ និងទឹកក្នុងមហាសមុទ្រទាំង ៤ បណ្តាទឹកទាំងពីរនោះ ទឹកណាច្រើនជាង ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយយល់ច្បាស់នូវធម៌ តាមដែលព្រះមានព្រះភាគសំដែងហើយ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយ អន្ទោលទៅត្រាច់រង្គាត់ទៅ ត្រូវគេកាត់ក្បាលដោយជាអង្វែងនេះ ឈាមដែលហូរស្រក់ទៅច្រើនអនេក ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនច្រើនជាងឡើយ ។

ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ច្បាស់នូវធម៌ តាមដែលតថាគតសំដែងហើយយ៉ាងនេះ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់ទៅត្រូវគេកាត់ក្បាលដោយជាអង្វែងនេះ ឈាមដែលហូរស្រក់ទៅច្រើនអនេក ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនច្រើនជាងមែន ។

ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយកើតជាគោ មានសភាពជាគោ ត្រូវគេកាត់ក្បាលអស់កាលជាអង្វែង ឈាមដែលហូរស្រក់ទៅច្រើនអនេក ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនច្រើនជាងមែនឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយកើតជាក្របី មានសភាពជាក្របី ត្រូវគេកាត់ក្បាលអស់កាលជាអង្វែង ឈាមដែលហូរស្រក់ទៅច្រើនអនេក ។

ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយកើតជាចៀម មានសភាពជាចៀម អស់កាលជាអង្វែង ។បេ។ កើតជាពពែ មានសភាពជាពពែ ។បេ។ កើតជាជ្រូក មានសភាពជាជ្រូក ។បេ។ កើតជាមាន់ មានសភាពជាមាន់ ។បេ។

ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ ត្រូវគេប្រចាប់ថាជាចោរបៀតបៀនអ្នកស្រុក ហើយគេកាត់ក្បាលអស់កាលជាអង្វែង ឈាមដែលហូរស្រក់ទៅច្រើនជាង ។

ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ ត្រូវគេប្រចាប់ថាជាចោរចាប់ស្ទាក់ក្បែរផ្លូវ អស់កាលជាអង្វែង ។បេ។ កាលដែលអ្នកទាំងឡាយ ត្រូវគេប្រចាប់ថាជាចោរលួចប្រពន្ធគេ ហើយគេកាត់ក្បាល ឈាមដែលហូរស្រក់ទៅច្រើនអនេក ឯទឹកក្នុងមហាសមុទ្រ

*ទាំង ៤ មិនមែនច្រើនជាងឡើយ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុត គេមិនអាចដឹងបាន ។បេ។ គួរជិនធ្នន់ ។*

*លុះព្រះមានព្រះភាគទ្រង់ត្រាស់សូត្រនេះចប់ហើយ ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីត្រេកអរ បានត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគទ្រង់ត្រាស់វេយ្យាករណ៍នេះ ចិត្តរបស់**បាវេយ្យកភិក្ខុ** ប្រមាណ ៣០ រូប ក៏រួចស្រឡះចាកអាសវៈ ដោយការមិនប្រកាន់ ។*

*(សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ អនមតគ្គសំយុត្ត ទុតិយវគ្គ តឹសមត្តសូត្រ បិដកលេខ ៣២ ទំព័រ ៩៧)*

*ភិក្ខុទាំងនោះបានសម្រេចព្រះអរហត្ត ហើយហោះទៅកាន់អាកាស ។*

*(សមន្តបាសាទិកា អដ្ឋកថា ព្រះវិន័យ)*

*ដូច្នេះហើយត្រាស់ហៅភិក្ខុទាំងឡាយថា*

**អនុជានាមិ ភិក្ខវេ វស្សំវុដ្ឋានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ។**

*ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុ ដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន ។*

**អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ អនាមន្តចារោ អសមាទានចារោ គណភោជនំ យាវទត្ថចីវរំ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ។**

*ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបានក្រាលកឋិនហើយ នឹងសម្រេចអានិសង្ស ៥ យ៉ាង គឺត្រាច់ទៅ (ណា) មិនបាច់លា (ភិក្ខុផងគ្នា) ១ ត្រេចទៅ (ណា) មិនបាច់*

យកត្រៃចីវរ (គ្រប់ប្រដាប់) ១ (ផាន់) គណភោជនបាន ១ (ទុកដាក់) អតិរេកចីវរបានតាមត្រូវការ ១ ចីវរណាដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុទាំងនោះ ១ ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង ៥ នេះនឹងសម្រេចដល់អ្នកទាំងឡាយដែលបានក្រាលកឋិន ។

ម្នាលភិក្ខុទាំងឡាយ ក៏ឯកឋិន (នោះ) ត្រូវអ្នកទាំងឡាយក្រាលយ៉ាងនេះ ។ គឺត្រូវឲ្យភិក្ខុអ្នកឆ្លាសប្រតិពលប្តឹងសង្ឃឲ្យដឹងថា

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃឲ្យសំពត់កឋិននោះដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ (ឥឡូវ) សង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន ។ ការឲ្យសំពត់កឋិននេះដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិន (បើ) គួរដល់លោកដ៏មានអាយុអង្គណា ត្រូវលោកដ៏មានអាយុអង្គនោះស្ងៀម (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណាទេ ត្រូវលោកដ៏មានអាយុអង្គនោះនិយាយឡើង ។ សំពត់កឋិននេះសង្ឃឲ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិនហើយ ។ ការឲ្យសំពត់កឋិននេះដល់ភិក្ខុឈ្មោះនេះ ទំនងជាគួរដល់សង្ឃហើយ ព្រោះហេតុនេះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវការនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

(វិនយបិដក មហាវគ្គ កឋិនក្ខន្ធកៈ បិដកលេខ ៨ ទំព័រ ៣-៤)

# អានិសង្សបុណ្យកឋិន

## អានិសង្សរបស់ភិក្ខុអ្នកក្រាលគ្រង និងអនុមោទនាមាន ៥យ៉ាងគឺះ

**១-អនាមន្តចារោ** ភិក្ខុត្រាច់ចរទៅកាន់ទីដទៃដោយមិនបាច់លាភិក្ខុផងគ្នា គឺរួចចាកអាបត្តិនៅក្នុងចារិត្តសិក្ខាបទទី ៦ អចេលួកវគ្គ សុទ្ធិកបាចិត្តិយ ។
**២-អសមាទានចារោ** ភិក្ខុត្រាច់ទៅកាន់ទីដទៃដោយមិនបាច់យកត្រៃចីវរគ្រប់ទាំង ៣ ទៅជាមួយបាន ដោយរួចចាកអាបត្តិនៅក្នុងទុតិយកឋិន សិក្ខាបទទី ២ ចីវរវគ្គ និស្សគ្គិយបាចិត្តិយ។
**៣-គណភោជនំ** ភិក្ខុទទួលឆាន់គណភោជន គឺភោជនដែលគេនិមន្តចំពោះឈ្មោះភត្ត រួចចាកអាបត្តិនៅក្នុងគណភោជន សិក្ខាបទទី ២ នៃភោជនវគ្គ សុទ្ធិកបាចិត្តិយ។

**៤-យាវទត្ថចីវរំ** ភិក្ខុទុកដាក់អតិរេកចីវរបានតាមត្រូវការ រួចចាកអាបត្តិក្នុងបឋមកឋិន សិក្ខាបទទី ១ ចីវរវគ្គ និស្សគ្គិយបាចិត្តិយ។
**៥-យោ ច តត្ថ ចីវរុប្បាទោ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ចីវរណាដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុទាំងនោះ ។

## អានិសង្ស ៥ យ៉ាង នៃការថ្វាយសំពត់កឋិន

**១-ភិក្ខុបញ្ញា វិសារទោ** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានបញ្ញាដ៏ច្រើន។
**២-សុរូបតា** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានរូបល្អ ។
**៣-សុវណ្ណតា** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានពណ៌សម្បុរកាយស្អាតល្អ ។

**៤-សុសណ្ឋានា** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានរូបរាងទ្រង់ទ្រាយស្អាតល្អ ។
**៥-ចក្កវត្តិរាជា ហោតិ** ដោយអំណាចនៃបុណ្យ រមែងបានកើតជាស្តេចចក្រពត្តិ ។

## អានិសង្ស ៥ យ៉ាង នៃការថ្វាយសំពត់កឋិន

**១. សុរូបតា** មានរូបស្អាត ធ្វើឲ្យបុរសស្ត្រី ឃើញហើយស្រលាញ់ពេញចិត្តជារូបមានសម្ផស្សគរស្ម័គ្រស្មាគមនិយមមេត្រី ភាព ។
**២. សុវណ្ណតា** មានសម្បុរស្អាត ម៉ដ្ឋខៃ ពុំមានស្លាកស្នាមឬប្រជ្រុលជាដើមមិនខ្មៅស្រិល មិន

សស្គុស មិនពពាលពព្រុស គឺសម្បុរល្អគួរជាទីចាប់ចិត្ត នៃអ្នកផងទាំងឡាយ ។

**៣. សុសណ្ឋានា** មានទ្រង់ទ្រាយ.កំពស់កំព.រាងរៅ សមសួនតាមកាលសម័យនៃអាយុកប្បនិមួយៗ ។

**៤. ចក្កវត្តិរាជា ហោតិ** ត្រូវបានជាស្ដេចចក្រពត្រាធិរាជ ប្រកបដោយទសពិធរាជធម៌ ក្នុងជាតិណាមួយដាច់ខាត ។

**៥. ឯហិភិក្ខុ** នឹងបានឯហិភិក្ខុ ក្នុងអវសានជាតិ ហើយសម្រេចអរហត្តមគ្គអរហត្តផល ដល់ព្រះនិព្វាន ។ បើស្ត្រីភេទ ក៏នឹងបានអារលតាមហាបសាទ ឬបានលុះមគ្គផលក្នុងជាតិជាទីបំផុតមិនខាន ៕

# អានិសង្សបរិក្ខារទាន

*ជនទាំងឡាយឯណាជាអ្នកប្រាជ្ញ បានឲ្យបាត្រជាទាន, ជនទាំងឡាយនោះ ជាអ្នកមានកម្លាំងនិងសេចក្ដីព្យាយាមច្រើន ឥតមានញៀវញើរ បរិបូណ៌ដោយឫទ្ធិ មានតេជះច្រើន ជាទីស្រឡាញ់នៃជន មានបរិវាររាប់មិនអស់ ប្រដាប់ដោយភោគសម្ប័ទគ្រប់យ៉ាង បានជាស្ដេចចក្រពត្តិ បរិបូណ៌ដោយកែវ ៧ ប្រការ មានមហិទ្ធិឫទ្ធិបរិបូណ៌ ដោយសម្បត្តិជាកាមាវចរ រូបាវចរនិងអរូបាវចរសោយសេចក្ដីសុខជាជាលោកិយ, បើកើតក្នុងពុទ្ធុប្បាទ នឹងបានជាអ្នកប្រាជ្ញណែនាំបង្ហាញប្រយោជន៍ដល់សត្វ ក្នុងលោកទាំងមូល ជាម្ចាស់សព្វសត្វទាំងឡាយ, លុះចំណេរទៅឯក្នែក នឹងបានត្រាស់ជាព្រះពុទ្ធ ។*

*ជនទាំងឡាយឯណា បានឲ្យសង្ឃាដី, ជនទាំងឡាយនោះជាអ្នកញាំញីមារសេនាទុកជាប្រទះនឹងផ្គររន្ទះខ្លាំងយ៉ាងណា ក៏មិនរំជួយរោមឡើយ មិនមានភ័យព្រឺស្បែកព្រឺរោមឡើយ, បានសោយសេចក្ដីសុខជាកាមភូមិ លុះចំណេរទៅឯក្នែកនឹងបានត្រាស់ជាព្រះពុទ្ធ ។*

*អ្នកឲ្យចីវរជាទាន នឹងឈ្នះសង្គ្រាម បានជាឥស្សរកំពូលឥសូរនៃជនទាំងអស់ លុះដល់កាលខាងក្រោយ នឹងបានត្រាស់ជាព្រះពុទ្ធ ។*

*អ្នកឲ្យស្បង់ជាទាន រមែងបានជាអ្នកស្អាត បរិសុទ្ធក្នុងភពទាំងឡាយ ជាធំក្នុងទីសព្វកន្លែង, លុះពេលខាងក្រោយនឹងបានត្រាស់ជាព្រះពុទ្ធ ។*

អ្នកឲ្យវត្តពន្ធជាទាន រមែងបានជាអ្នកស្អាត បរិសុទ្ធក្នុងភពទាំងឡាយជាធំក្នុងទីសព្វកន្លែង, លុះពេលខាងក្រោយនឹងបានត្រាស់ជាព្រះពុទ្ធ ។

អ្នកដែលបរិសុទ្ធផុតពៀរវេរា បរិបូណ៌ដោយលក្ខណ៍ មានអាយុវែង មានសេចក្ដីសុខទាំងនេះជាផលនៃកាំបិតកោរ ។

ជនទាំងឡាយឯណា កើតក្នុងកាលគួរ មានប្រាជ្ញាមុះមុត ចេះដឹងអាថ៌សេចក្ដីសព្វគ្រប់ អង់អាច មានជ័យជម្នះឈ្នះវាទទាំងពួង, ជនទាំងឡាយនោះលុះដល់ពេលខាងក្រោយនឹងបានត្រាស់ជាព្រះពុទ្ធ ។

ជនទាំងឡាយឯណា បានអញ្ចុលជាទានដោយសទ្ធា ជនទាំងឡាយនោះនឹងមានអាយុវែង មានប្រាជ្ញាថ្លាស្អាត ជាពហុស្សូតទ្រទ្រង់ធម៌ មានរូបល្អប្រាកដក្នុងលោក ។

ជនទាំងឡាយឯណា ឲ្យសំពត់តម្រងទឹកដល់ភិក្ខុ ជនទាំងឡាយនោះលុះកើតក្នុងជាតិទាំងពួង រមែងឆ្ងៀវឆ្ងាសប្រាសចាកពៀរវេរា ត្រេកត្រអាលក្នុងឋានសួគ៌ មានរូបល្អ មានសម្បុរល្អ មានអាយុវែង មានឥន្ទ្រិយមិនលំបាក ។

ជនទាំងឡាយឯណា បានឲ្យឆត្រជាទានក្នុងពេលក្ដៅ ទោះឆត្រមានក្ដី ឆត្រស្វាបក្បោកក្ដី ឆត្រកែវក្ដី, ជនទាំងឡាយនោះរមែងបាននូវពួកបក្ខដ៏ប្រសើរជានិច្ច ។ អ្នកឲ្យឆត្រជាទានក្នុងពេលក្ដៅនោះ រមែងបានគ្រឿងកកុធភណ្ឌ ៥ យ៉ាងគឺៈ ស្វេតឆត្រ ១ ចាមរ ១ មកុដ ១ ព្រះខាន់ ១ សុពណ៌បាទុក ១ ។

អ្នកមានសទ្ធាបរិសុទ្ធ បានប្រគេនរបស់ប្រកបដោយអង្គ ៨ ជាទ្រព្យប្រសើរដល់ភិក្ខុទាំងឡាយ គឺត្រៃចីវរ ១ បាត្រ ១ កាំបិតកោរ ១ អញ្ចុល ១ វត្តពន្ធ ១ តម្រងទឹក ១ អ្នកនោះនឹងមានបរិវាររាប់មិនអស់ មានស័ក្ដិយសខ្ពស់អនេក ។

អ្នកឲ្យកម្រាលស្បែកជាទាន នឹងបានជាស្ដេចចក្រពត្តិ មានឫទ្ធិច្រើន មនុស្សក្នុងលោកទាំងអស់តែងស្រឡាញ់ចូលចិត្ត រមែងវៀរចាកភពមានរូបភពជាដើម ។

អ្នកឲ្យចីវរជាទាន នឹងបានសម្បត្តិច្រើន មានឫទ្ធិច្រើន បរិបូណ៌ដោយកម្លាំងច្រើន, លុះចំណេរទៅឯភ្នែក នឹងបានដល់នូវព្រះនិព្វានជាឋានរលត់ទុក្ខ ។

*នរៈនារី ដែលបានឲ្យគ្រឿងបរិក្ខារគ្រប់ប្រដាប់ នឹងបានសម្បត្តិទិព្វ ខ្ញុំប្រុសខ្ញុំស្រីរាប់មិនបាន សោយសេចក្តីសុខក្នុងកាមលោក ដល់នូវសេចក្តីសុខក្នុងរូបលោក អរូបលោក, លុះចំណេរទៅឯក្អែក នឹងបានដល់នូវព្រះនិព្វាន ។*

*ភិក្ខុដែលប្រាថ្នាលោកុត្តរធម៌ ៩ យ៉ាង គួរបំពេញបារមី ៣០ ប្រការ ឲ្យគ្រប់ទាំងអស់ ដោយយល់ឃើញថា ទានបារមីជាឫសគល់, ព្រះពុទ្ធគ្រប់អង្គទ្រង់សរសើរជានិច្ច អ្នកដែលមានបារមីគ្រប់គ្រាន់ហើយ រមែងដល់នូវព្រះនិព្វានជាប្រាកដ ។ លុះដល់ព្រះអរិយមេត្តេយ្យមកឧប្បត្តិក្នុងជម្ពូទ្វីប ជនដែលបានឲ្យទាននោះ នឹងបានជាឯហិភិក្ខុក្នុងសំណាក់ព្រះអង្គ ប្រដាប់ដោយបាត្រ និងចីវរ ជាពុទ្ធបុត្រមានបញ្ញាច្រើន សម្រេចដូចសេចក្តីប្រាថ្នា, ទាំងនេះក៏ព្រោះឲ្យទានគ្រឿងអដ្ឋបរិក្ខារ រមែងបានសព្ទសាធុការពរអំពីទេវតាទាំងឡាយ ដោយអានុភាពនៃគ្រឿងបរិក្ខារ, ព្រោះហេតុនោះ បណ្ឌិតអ្នកមានប្រាជ្ញាច្រើន កាលបើបានជ្រាបថាឲ្យទានគ្រឿងបរិក្ខារមានផលច្រើនយ៉ាងនេះហើយ គប្បីឲ្យទានក្នុងកាលដែលមានសាសនាព្រះសម្មាសម្ពុទ្ធ ។*

(ចាកមហាសុរសេនជាតក ក្នុងបញ្ញាសជាតក)

# ឧបនិស្ស័យឯហិភិក្ខុ

(ការសម្រេចជាឯហិភិក្ខុបានដោយផលនៃការថ្វាយបាត្រចីវរ ឬអដ្ឋបរិក្ខារ)




*ពាក្យថា* **ឯហិ ភិក្ខូតិ ភគវា អវោច** *ព្រះមានព្រះភាគត្រាស់ថា* **អ្នកចូរមកជាភិក្ខុចុះ** *សេចក្ដីថា បានឮថា ព្រះមានព្រះភាគទ្រង់ប្រមើលមើលឧបនិស្ស័យនៃបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិរបស់***យសកុលបុត្រ***នោះ ទ្រង់ឃើញការថ្វាយ***អដ្ឋបរិក្ខារ** *មានចីវរជាដើមក្នុងជាតិជាអនេក ហើយទើបត្រាស់ថា* **ឯហិ ភិក្ខុ អ្នកចូរមកជាភិក្ខុចុះ** *។ ក្នុងពេលនោះឯង*

*យសកុលបុត្រនោះ ក៏ជាមនុស្សដែលមានសក់កោរហើយ និងស្លៀកដណ្តប់កាសាវពស្ត្រ មានបរិក្ខាររបស់ភិក្ខុ ៨ យ៉ាង ក្នុងសរីរៈតែម្តង ហាក់បីដូចជាព្រះថេរៈដែលមានវស្សា ៦០ ហើយអង្គុយមនស្ការព្រះមានព្រះភាគ ។*

*បុគ្គលណាបានថ្វាយ***អដ្ឋបរិក្ខារ***មានចីវរជាដើមក្តី បានថ្វាយ***បាត្រនិងចីវរ***ប៉ុណ្ណោះក្តី ដល់ព្រះអរិយៈមានសោតាបន្នបុគ្គលជាដើម ឬដល់បុថុជ្ជនដែលជាអ្នកដល់ព្រមដោយសីល ហើយតាំងសេចក្តីប្រាថ្នាទុកថា* **ឥទំ បរិក្ខារទានំ អនាគតេ ឯហិភិក្ខុភាវាយ បច្ចយោ ហោតុ** *បរិក្ខារទាននេះ សូមចូរជាបច្ច័យនៃភាពជាឯហិភិក្ខុ ក្នុងកាលជាអនាគតចុះ ។ កាលដល់ព្រមដោយអធិការសម្បត្តិតាមដែលប្រាថ្នាទុកនោះ គប្បីជ្រាបថា រមែងប្រព្រឹត្តទៅដើម្បីបានបរិក្ខារ ដែលសម្រេចដោយឫទ្ធិ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគដល់បុគ្គលនោះ ។*

*(សារត្ថទីបនីដីកា មហាខន្ធកៈ យសស្ស បព្វជ្ជាកថាវណ្ណនា)*

## អដ្ឋបរិក្ខារ ទសបរិក្ខារ ទ្វាទសបរិក្ខារ

**( បរិក្ខារ ៨ បរិក្ខារ ១០ បរិក្ខារ ១២ )**

*អដ្ឋបរិក្ខារ* គ្រឿងប្រើប្រាស់ ៨ យ៉ាង សម្រាប់ព្រះពុទ្ធនិងបព្វជិតពុទ្ធសាសនិកត្រូវមានគឺ *សង្ឃាដី, ឧត្តរាសង្គ*(ចីពរ), *អន្តរវាសក* (ស្បង់), *កាយពន្ធនៈ* (វត្ថពន្ធចង្កេះ), *បាត្រ* (ព្រមទាំងស្មោកនិងយោគផង), *កាំបិតកោរ*(ព្រមទាំងថ្មសំលៀងផង), *ម្ជុល*(ព្រមទាំងបំពង់ម្ជុលនិងចេសផង), *តម្រងទឹក*(ទាំងតួនិងសំពត់សម្រាប់ត្រងផង); ឯបរិក្ខារក្រៅពីនេះក៏ជាគ្រឿងប្រើប្រាស់ដែរ ហៅថា *បរិក្ខារពិសេស* ពុំរាប់ថាជា *អដ្ឋបរិក្ខារឡើយ* ។

*(វចនានុក្រម សម្តេចជោតញ្ញាណោ ជួនណាត)*

## ១. អដ្ឋបរិក្ខារ

| | |
|---|---|
| ១. សង្ឃាដិ | *សង្ឃាដី* |
| ២. ឧត្តរាសង្គោ | *ចីវរ* |
| ៣. អន្តរវាសកោ | *ស្បង់* |
| ៤. បត្តោ | *បាត្រ* |
| ៥. វាសិ | *កាំបិតកោរ* |
| ៦. សូចិ | *ម្ជុល* |
| ៧. ពន្ធនំ | *វត្ថពន្ធ* |
| ៨. បរិស្សាវនំ | *សំពត់តម្រងទឹក* |

*សមដូចពាក្យដែលលោកពោលទុកថា*

តិចីវរញ្ច បត្តោ ច, វាសិ សូចិ ច ពន្ធនំ;
បរិស្សាវេនេន អដ្ឋេតេ, យុត្តយោគស្ស ភិក្ខុនោ។

*(សមន្តបាសាទិកា អដ្ឋកថាវិនយ បារាជិកកណ្ឌ មេថុនធម្មសិក្ខាបទ, បបញ្ចសូទនី អដ្ឋកថា អង្គុលិមាលសូត្រ)*

## ២. ទសបរិក្ខារ

| | |
|---|---|
| ១. សង្ឃាដិ | *សង្ឃាដី* |
| ២. ឧត្តរាសង្គោ | *ចីវរ* |
| ៣. អន្តរវាសកោ | *ស្បង់* |
| ៤. បត្តោ | *បាត្រ* |
| ៥. វាសិ | *កាំបិតកោរ* |
| ៦. សូចិ | *ម្ជុល* |
| ៧. ពន្ធនំ | *វត្ថពន្ធ* |

| | |
|---|---|
| ៨. បរិស្សាវនំ | *សំពត់តម្រងទឹក* |
| ៩. កត្តរទណ្ឌោ | *ឈើច្រត់* |
| ១០. តេលណាឡិ | *នាឡិសម្រាប់ដួសប្រេង* |

## ៣. ទ្វាទសបរិក្ខារ

| | |
|---|---|
| ១. សង្ឃាដិ | *សង្ឃាដី* |
| ២. ឧត្តរាសង្គោ | *ចីវរ* |
| ៣. អន្តរវាសកោ | *ស្បង់* |
| ៤. បត្តោ | *បាត្រ* |
| ៥. វាសិ | *កាំបិតកោរ* |
| ៦. សូចិ | *ម្ជុល* |
| ៧. ពន្ធនំ | *វត្ថពន្ធ* |
| ៨. បរិស្សាវនំ | *សំពត់តម្រងទឹក* |
| ៩. កត្តរទណ្ឌោ | *ឈើច្រត់* |
| ១០. តេលណាឡិ | *នាឡិសម្រាប់ដួសប្រេង* |
| ១១. ឆត្តំ | *ឆត្រ* |
| ១២. ឧបាហនា | *ស្បែកជើង* |

*(អភិធានប្បទីបិកាដីកា)*

*(រៀបរៀងដោយខេមរ អភិធម្មាវតារ)*